**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**
.សំណុំរឿងព្រហ្មទណ្ឌលេខ២០០៣
អក ថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ២០២១
.ជំនុំជំរះលេខ ០៥២ ជរ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២២
.សាលក្រមលេខ ៥០ (ប)
ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២

# <u>តាមនាមប្រជារាស្ត្រខ្មែរ</u>

## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល ។

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ២០០៣ អក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២១ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] សុភារៈ ភេទប្រុស អាយុ ១៦ ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល នៅលីវ ឪពុកឈ្មោះ [redacted] សុផានពង្ស(រស់) ម្ដាយឈ្មោះ [redacted] សុគន្ធី (រស់) ទោសពីមុនគ្មាន។ **(ឃាត់ខ្លួនថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ២០២១ និងឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ ៤៨៦១ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល)** ។

ជាប់ចោទពីបទៈរក្សាទុក. ចាត់ចែង .សម្រួលឱ្យប្រើប្រាស់និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតារាមដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០២១ តាមមាត្រា ៤០ មាត្រា ៤២ កថាខណ្ឌទី៣ ចំណុចទី២ និងចំណុចទី៣ មាត្រា ៤៤ កថាខណ្ឌទី២ ចំណុចទី៣ និងចំណុចទី៤ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ជនជាប់ចោទឈ្មោះ [redacted] ចិន្ដា ហៅ ចិន ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល នៅលីវ ឪពុកឈ្មោះ [redacted] សាន (រស់)ម្ដាយឈ្មោះ [redacted] សុវ៉ា (រស់) ទោសពីមុនគ្មាន ។ **(ឃាត់ខ្លួននៅថ្ងៃទី**

៣០ ខែ វិច្ឆិកា ឆ្នាំ ២០២១ ឃុំខ្លួនតាមដីកាលេខ: ៤៨៦៣ ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ) ។

ជាប់ចោទពីបទ: រក្សាទុក.ចាត់ចែង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតារាមដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០២១ តាមមាត្រា៤០ មាត្រា៤២ កថាខណ្ឌទី៣ ចំណុចទី២ និងចំណុចទី៣ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សុភារៈ អាយុ ១៦ ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted]ចិន្តា ។

-បានឃើញរបាយការណ៍បញ្ជាក់រឿងហេតុលេខ: ០៧៣ របក ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ២០២១ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ នៃស្នងការនគបាលខេត្តកណ្តាល ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ០៣៧ ដកសព ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញដីកាដំណោះស្រាយលេខ: ០៥៥ ដកដស ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

**អង្គហេតុនៃរឿងមានដូចតទៅ៖**

កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ម៉ោង ១០.៤៨ នាទី ជនសង្ស័យឈ្មោះ [redacted]សុភារៈ និងឈ្មោះ [redacted] ចិន្តា ហៅ ចិនបានទិញថ្នាំញៀនដើម្បីសេពជាមួយមិត្តភក្តិរបស់ខ្លួននៅឯផ្ទះជនសង្ស័យឈ្មោះ[redacted]សុភារៈ។ខណៈពេលជនសង្ស័យខាងលើកំពុងប្រើប្រាស់គ្រឿងញៀនក៏ត្រូវបានសមត្ថកិច្ចចុះមកធ្វើការចាប់ខ្លួនជនសង្ស័យចំនួន ១០នាក់ នូវចំណុចភូមិតារាបដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដកហូតបានវត្ថុតាង ម្សៅក្រោមពណ៌សថ្លាចំនួន ៩កញ្ចប់ ទម្ងន់២.៧១ក្រាម។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted] សុភារៈ បានឆ្លើយសារភាពថា សមត្ថកិច្ចឃាត់ខ្លួននៅបន្ទប់ជួលបានថ្នាំញៀនចំនួន៩កញ្ចប់ប្រភេទម៉ាទឹកកក។ គ្រឿងញៀននេះ ឈ្មោះ ហេង យកមកឱ្យឈ្មោះ[redacted] ចិន្តា។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនរយៈពេល៦ខែមកហើយ ហើយឈ្មោះ [redacted] ចិន្តាជាអ្នកស្គាល់គ្នា ការប្រើប្រាស់គ្រឿងញៀនគឺដក់នៅក្នុងបន្ទប់ជួលរបស់ខ្លួនដោយឈ្មោះ [redacted] ចិន្តា មកដក់នៅទីនេះ។ ជាទូទៅ ខ្លួនចូលលុយគ្នាជាមួយឈ្មោះ [redacted] ចិន្តា ម្នាក់ចំនួន២ម៉ឺនរៀលទិញបានចំនួន១កញ្ចប់។ ថ្នាំញៀននេះ ឈ្មោះ ចិន្តា ជាអ្នកទិញដោយ ចិន្តា ប្រគល់ប្រាក់ឱ្យឈ្មោះ រាជ ។

-ជនជាប់ចោទឈ្មោះ [redacted]ចិន្តា បានឆ្លើយសារភាពថា នៅថ្ងៃកើតហេតុសមត្ថកិច្ចដកហូតគ្រឿងញៀន ៩កញ្ចប់ជាប្រភេទម៉ាទឹកកកដែលគ្រឿងញៀនទិញពីឈ្មោះ រាជ តំលៃចំនួន ៨៥០០០ រៀល គោលបំណងយកមកប្រើប្រាស់នៅផ្ទះជួលរបស់ឈ្មោះ [redacted] សុភារៈ និង សំភារៈប្រើប្រាស់គ្រឿងញៀនគឺផ្ទះរបស់សុភារៈមានស្រាប់។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនប្រហែល៧ទៅ៨ខែ ។ គ្រឿងញៀននេះឈ្មោះ សុភារៈ ពុំបានចូលលុយទេ ហើយខ្លួនយកប្រើប្រាស់គ្នាប្រហែល ១០ នាក់។



Scanned with CamScanner

-សាក្សីបំភ្លឺឈ្មោះ [redacted]អៀនអាន អធិការរងស្រុកកៀនស្វាយ បានបញ្ជាក់ថា នៅវេលាកើតហេតុខាងលើមានប្រជាពលរដ្ឋរាយការណ៍មកប៉ុស្តិ៍ថា មានការប្រើប្រាស់គ្រឿងញៀន ។ កម្លាំងក៏បានចុះពិនិត្យដល់ផ្ទះជនជាប់ចោទ ហើយដកគ្រឿងញៀនពីឈ្មោះ [redacted] ចិន្តា ។ ផ្ទះនេះពុំមែនផ្ទះជួលទេ ជាផ្ទះរបស់ម្តាយគាត់ ។ ថ្នាំញៀន១កញ្ចប់តំលៃ៤ម៉ឺនរៀល, កញ្ចប់ធំ ១០ ម៉ឺនរៀល ។ ឈ្មោះ [redacted] ចិន្តា ជាមេគ្រឿងញៀន ។ ផ្ទះកើតហេតុនេះមានធុំក្លិនគ្រឿងញៀន ។ ជា ទូទៅឈ្មោះ ចិន្តា ជាអ្នកទិញឱ្យចាត់ចែងឱ្យគ្នាគាត់ប្រើប្រាស់ដោយយកប្រាក់ពីអ្នកដក់គ្នាគាត់ ។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុតាងរបស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០២១ មានម្សៅក្រាមពណ៌សថ្លាសង្ស័យសារធាតុញៀន (ម៉ាទឹកកក) ចំនួន ០៩ កញ្ចក់ (មធ្យម០១ តូច ០៨) ទម្ងន់ ០.៧២ ក្រាម និង១.៩៩ ក្រាម វិចខ្ចប់ដាក់ក្នុងស្រោមសំបុត្រពណ៌គគីធំចំនួន ០២ គ្មានលេខកូត ទូរស័ព្ទអុិនចុចពិលចំនួន០២ គ្រឿង (មិនប្រក្រតី) សម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ហើយជនជាប់ចោទឈ្មោះ ពង្ស សុភារៈ និងជនជាប់ចោទឈ្មោះ [redacted] ចិន្តា ហៅក្រៅ ចិន ជាអ្នកទិញ ហើយយកមកប្រើប្រាស់ ដោយសារមានប្រជាពលរដ្ឋរាយការណ៍មកសមត្ថកិច្ចក៏បានចុះពន្លឺផ្ទះរបស់ជនជាប់ចោទដកហូតបានគ្រឿងញៀនចំនួន ៩ កញ្ចប់ មានតូច៨ និងមធ្យម១ មានទម្ងន់ ២,៧១ក្រាម ។ ជនជាប់ចោទបានហៅជនជាប់ចោទជារងគ្រោះឱ្យប្រើប្រាស់នៅផ្ទះទីនោះ។ ជនជាប់ចោទឈ្មោះ [redacted] ចិន្តា ក៏បានបញ្ជាក់ថា ខ្លួនជាអ្នកទិញគ្រឿងញៀនពីឈ្មោះ រាជ យកមកប្រើប្រាស់នៅផ្ទះម្តាយរបស់ឈ្មោះពង្ស សុភារៈ តាមការបំភ្លឺរបស់លោកអធិការរង, តាមការបំភ្លឺសមត្ថកិច្ចថា កញ្ចប់តូចតំលៃ៤ម៉ឺនរៀល ,កញ្ចប់មធ្យមតំលៃ ១០ ម៉ឺនរៀល ។ ដូច្នេះ តំណាងអយ្យការស្នើសុំតំកល់បទចោទទុកដដែល ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សុភារៈ និងឈ្មោះ [redacted] ចិន្តា ថា ក្រោយពីបានការដេញដោលសវនាការឃើញថា ឈ្មោះ [redacted]សុភារៈ ជាអនីតិជន ស្នើសុំបន្ធូរបន្ថយទោស ។ ឈ្មោះ[redacted] ចិន្តា ជាអ្នកទទួលគ្រឿងញៀនពីឈ្មោះ ណុល និងឈ្មោះ រាជ ហើយកូនក្តីខ្លួនយកមកចាត់ចែងបន្ត ។ ថ្នាំញៀននេះសមត្ថកិច្ចដកហូតពីឈ្មោះ [redacted]ចិន្តា ។ ស្នើសុំពិចារណាបទរក្សាទុក.ចាត់ចែងប្រើប្រាស់គ្រឿងញៀន ។

+ជនជាប់ចោទឈ្មោះ[redacted] សុភារៈ និយាយសំដីចុងក្រោយថា៖ ស្នើសុំបន្ធូរបន្ថយទោស ។

+ជនជាប់ចោទឈ្មោះ[redacted] ចិន្តា និយាយសំដីចុងក្រោយថា៖ ស្នើសុំបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ឯកសារ និងវត្ថុតាង

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។



Scanned with CamScanner

## សំអាងហេតុ

១- តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌ ពីចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ដែលមានជនជាប់ចោទឈ្មោះ [redacted] សុភារៈ ភេទប្រុស អាយុ ១៦ ឆ្នាំ ជនជាតិខ្មែរ ពីបទ រក្សាទុក ចាត់ចែង សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។ ចំណែកឯឈ្មោះ [redacted] ចិន្តា ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិខ្មែរ ពីបទ រក្សាទុក ចាត់ចែង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមដីកាដំណោះស្រាយលេខ ០៥៥ ដកដស ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ ២០២២ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទ យោងតាមមាត្រា២៨៩-មាត្រា ២៩១ និងមាត្រា៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ផ្អែកតាមរបាយការណ៍របស់សមត្ថកិច្ច ,ចម្លើយសារភាពរបស់ជនជាប់ចោទ នៅគ្រប់ដំណាក់កាល ព្រមទាំងភស្តុតាងនានា ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុភារៈ និងជាប់ចោទឈ្មោះ [redacted] ចិន្តា ហៅ ចិន ពិតជាបានរក្សាទុក. ចាត់ចែង.សំរួលប្រើប្រាស់និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដោយហេតុថា នៅថ្ងៃកើតហេតុ មន្ត្រីសមត្ថកិច្ចក៏បានធ្វើការរុករកឃើញថ្នាំញៀនខាងលើផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] សុភារៈ ក៏បានឃើញម្សៅក្រាមពណ៌សថ្លាសង្ស័យសារធាតុញៀន (ម៉ាទឹកកក) ចំនួន ០៩ កញ្ចប់ទម្ងន់ ២,៧១ក្រាមដូចមាននៅក្នុងកំណត់ហេតុធ្វើតេស្តបឋមវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២១ របស់អធិការស្រុកកៀនស្វាយ គឺ ធំចំនួន ០២ គ្មានលេខកូត ទូរស័ព្ទអ៊ិនចុចពិលចំនួន ០២ គ្រឿង ( មិនប្រក្រតី )សម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន និង ឃាត់ខ្លួនជនសង្ស័យចំនួន១០នាក់។អំពើជនជាប់ចោទឈ្មោះ ពង្ស សុភារៈ គឺជាអង្គហេតុត្រូវនឹងធាតុផ្សំនៃបទល្មើសពីបទៈរក្សាទុក. ចាត់ចែង សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងតាមមាត្រា៤០ មាត្រា ៤២ កថាខណ្ឌទី៣ ចំណុចទី២ និងចំណុចទី៣ មាត្រា ៤៤កថាខណ្ឌទី២ ចំណុចទី៣ និងចំណុចទី៤ មាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។ ចំពោះជនជាប់ចោទឈ្មោះ សឿន ចិន្តា គឺជាអង្គហេតុត្រូវនឹងធាតុផ្សំបទល្មើសពីបទៈ រក្សាទុក.ចាត់ចែង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងតាមមាត្រា ៤០ មាត្រា ៤២ កថាខណ្ឌទី៣ ចំណុចទី២ និងចំណុចទី៣ មាត្រា ៤៤ កថាខណ្ឌទី២ ចំណុចទី៣ និងចំណុចទី៤ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣- តាមកំណត់ហេតុទទួលវត្ថុតាង កាលថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០២១ មានម្សៅក្រាមពណ៌សថ្លាសង្ស័យសារធាតុញៀន (ម៉ាទឹកកក) ចំនួន ០៩ កញ្ចក់ (មធ្យម០១ តូច ០៨) ទម្ងន់ ០.៧២ក្រាម និង១.៩៩ ក្រាម វិចខ្ចប់ដាក់ក្នុងស្រោមសំបុត្រពណ៌គគីធំចំនួន ០២ គ្មានលេខកូត ទូរស័ព្ទអ៊ិនចុចពិលចំនួន០២ គ្រឿង(មិនប្រក្រតី)សម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន ចំណុចនេះបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

៤- ជនជាប់ចោទឈ្មោះ [redacted] សុភារៈ ជាអនីតិជន និងជនជាប់ចោទឈ្មោះ [redacted] ចិន្តា ហៅ ចិន មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន ។

៥- សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការបានចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] សុភារៈ និងឈ្មោះ [redacted] ចិន្តា ហៅ ចិន ចំពោះបទល្មើសខាងលើ តំណាងអយ្យការសុំតម្កល់បទចោទប្រកាន់នេះទុកដដែលនោះ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។



Scanned with CamScanner

៦-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភារៈ ស្នើសុំសំរាលទោស ដោយមូលហេតុថា កូនក្តីរបស់ខ្លួនជាអនីតិជន ចំណុចនេះក្រុមប្រឹក្សានឹងពិចារណា ។

៧- មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទតទៅ៖

ក/ឈ្មោះ [redacted] សុភារៈ ពីបទ រក្សាទុក ចាត់ចែង សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតារាបដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ តាមមាត្រា ៤០ មាត្រា៤២ កថាខណ្ឌទី៣ ចំណុចទី២ និងចំណុចទី៣ មាត្រា ៤៤ កថាខណ្ឌទី២ ចំណុចទី៣ និងចំណុចទី៤ និងមាត្រា៤៥ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ/ជនជាប់ចោទឈ្មោះ [redacted] ចិន្តា ហៅចិន ពីបទៈ រក្សាទុក ចាត់ចែង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតារាបដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលត្រូវផ្តន្ទាទោសតាមមាត្រា យោងតាមមាត្រា ៤០ មាត្រា៤២ កថាខណ្ឌទី៣ ចំណុចទី២ និងចំណុចទី៣ មាត្រា ៤៤ កថាខណ្ឌទី២ ចំណុចទី៣ និងចំណុចទី៤ និងមាត្រា៤៥ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨- អំពើដែលជនជាប់ចោទឈ្មោះ [redacted] សុភារៈ ជាអនីតិជន និងជនជាប់ចោទឈ្មោះ [redacted] ចិន្តា ហៅ ចិន ជានីតិជន បានប្រព្រឹត្តបាន ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម។ ដូច្នេះទណ្ឌកម្ម ដែលត្រូវអនុវត្តលើជនជាប់ចោទនីមួយៗតុលាការនឹងពិចារណា ។

**<u>ហេតុដូច្នេះសម្រេច</u>**

១- ផ្តន្ទាទោស៖

ក/ឈ្មោះ [redacted] សុភារៈ ភេទប្រុស អាយុ១៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ២ (ពីរ)ឆ្នាំ ៦(ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន ៥.០០០.០០០ (ប្រាំលាន)រៀល ពីបទៈ រក្សាទុក ចាត់ចែង សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតារាបដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២១ តាមមាត្រា ៤០ មាត្រា៤២ កថាខណ្ឌទី៣ ចំណុចទី២ និងចំណុចទី៣ មាត្រា ៤៤ កថាខណ្ឌទី២ ចំណុចទី៣ និងចំណុចទី៤ និងមាត្រា៤៥ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

ខ/ឈ្មោះ [redacted] ចិន្តា ហៅ ចិន ភេទប្រុស អាយុ ២២ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ៥ ( ប្រាំ ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ពីបទៈ រក្សាទុក . ចាត់ចែង និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតារាបដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២១ តាមមាត្រា ៤០ មាត្រា ៤២ កថាខណ្ឌទី ៣ ចំណុចទី ២ និង ចំណុចទី ៣ មាត្រា៤៤ កថាខណ្ឌទី ២ ចំណុចទី៣ និង ចំណុចទី៤ មាត្រា ៤៥ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២- រឹបអូសវត្ថុតាងតាមកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០២១ មានម្សៅក្រាមពណ៌សថ្លាសង្ស័យសារធាតុញៀន (ម៉ាទឹកកក) ចំនួន ០៤ កញ្ចប់មានទម្ងន់ ២,៧១ក្រាម ជាសារធាតុមេតំហ្វេតាមីន ទូរស័ព្ទអ៊ិនចុចពិលចំនួន០២

គ្រឿង(មិនប្រក្រតី)សម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុភារៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចិន្តា ហៅ ចិន ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២២ រក្សាសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|

ហត្ថលេខាត្រា [redacted]

(<u>បានចម្លងត្រឹមត្រូវតាមច្បាប់ដើម</u>)

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក.ព.ស ២៥៦៥

កណ្តាល , ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២២

**បានឃើញ**

**ប្រធានក្រុមប្រឹក្សា**

[redacted]

**ក្រឡាបញ្ជី**

[redacted]